**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០៧ អនក្រ

**សេចក្តីសំរេច**

**ស្តីពី**

**ការបង្កើតគណៈកម្មការស្រាវជ្រាវអំពើហិង្សា**

**ដុតបំផ្លិចបំផ្លាញ និងអំពើឆក់ប្លន់ទៅលើស្ថានទូតនៃព្រះរាជាណាចក្រថៃ សណ្ឋាគារ**

**ក្រុមហ៊ុន ស្ថានីយ៍វិទ្យុ-ទូរទស្សន៍ និងទ្រព្យសម្បត្តិប្រជាពលរដ្ឋ**

**កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-ផ្អែកតាមការចាំបាច់

**សំរេច**

**ប្រការ១:** ត្រូវបានបង្កើតគណៈកម្មការស្រាវជ្រាវអំពើហិង្សាដុតបំផ្លិចបំផ្លាញ និងអំពើឆក់ប្លន់ទៅលើស្ថានទូតនៃព្រះរាជាណាចក្រថៃ សណ្ឋាគារ ក្រុមហ៊ុន ស្ថានីយ៍វិទ្យុ-ទូរទស្សន៍ និងទ្រព្យសម្បត្តិប្រជាពលរដ្ឋ ដែលមានសមាសភាពដូចតទៅ :

HQS-Royal Thai Embassy 2003

១-ឯកឧត្តម ឧត្តមសេនីយ៍ទោ **យូ ស៊ិនឡុង** ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ **ប្រធាន**

២-ឯកឧត្តម ឧត្តមសេនីយ៍ទោ **សុខ ផល** ប្រធាននាយកដ្ឋានពត៌មានទូទៅ **អនុប្រធាន**

៣-លោក ឧត្តមសេនីយ៍ត្រី **ខឹម ពិសេន** មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស **សមាជិក**

៤-លោក ឧត្តមសេនីយ៍ត្រី **គន្ធ សំអឿន** ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម **សមាជិក**

៥-លោក ឧត្តមសេនីយ៍ត្រី **សួន ឈាងលី** ស្នងការនគរបាលក្រុង **សមាជិក**

**ប្រការ២:** គណៈកម្មការមានភារកិច្ច :

-ធ្វើការស៊ើបអង្កេតប្រមែប្រមូលពត៌មាន កសិណសាក្សី ឯកសារ ខិតប័ណ្ណ រូបភាពសកម្មភាព ដើម្បីកំណត់ជនដៃដល់ធ្វើអំពើហិង្សា ដុតបំផ្លិចបំផ្លាញស្ថានទូតនៃព្រះរាជាណាចក្រថៃ ដុតបំផ្លាញ លួចប្លន់ទ្រព្យសម្បត្តិ សណ្ឋាគារ ក្រុមហ៊ុន ស្ថានីយ៍វិទ្យុ-ទូរទស្សន៍ និងទ្រព្យសម្បត្តិប្រជាពលរដ្ឋ ។

-ស៊ើបអង្កេតស្រាវជ្រាវរកមេក្លោង អ្នកញុះញង់ អ្នកនៅពីក្រោយខ្នងដែលបានឆ្លៀតយកឱកាស ដោយវិធីញុះញង់នូវពាក្យចចាមអារាមគ្មានការពិត ជំរុញឱ្យមានអំពើហិង្សា ការដុតបំផ្លិចបំផ្លាញ និងលួចឆក់ប្លន់ ។

-ធ្វើការសាកសួរបំភ្លឺជនសង្ស័យដែលបានចាប់ឃាត់ខ្លួនក្នុងការចូលរួមសកម្មភាពអំពើហិង្សា ការដុតបំផ្លិចបំផ្លាញ និងលួចឆក់ប្លន់នាត្រីថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៣។ លើមូលដ្ឋាននេះ ដើម្បីស្វែងរកចាប់ខ្លួនជនដៃដល់ អ្នកញុះញង់ អុជអាល និងអ្នកដែលនៅពីក្រោយខ្នង ជំរុញឱ្យកើតមាននូវសកម្មភាពខាងលើ និងរៀបចំកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីធ្វើការវិនិច្ឆ័យទោសតាមច្បាប់។

**ប្រការ៣:** គ្រប់ក្រសួង ស្ថាប័នត្រូវផ្តល់កិច្ចសហការជាមួយគណៈកម្មការនេះ ដើម្បីឱ្យរាល់កិច្ចដំណើរការស្រាវជ្រាវបានប្រព្រឹត្តទៅដោយជោគជ័យ ។

-គណៈកម្មការស្រាវជ្រាវករណី ត្រូវរាយការណ៍ជាបន្តបន្ទាប់ ជូនសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអគ្គស្នងការនគរបាលជាតិ អំពីលទ្ធផលនៃការស្រាវជ្រាវ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការឱ្យបានរហ័ស និងមានប្រសិទ្ធភាព ។

**<u>ប្រការ៤</u>:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស គ្រប់ប្រធានក្រសួង ស្ថាប័ន និងឯកឧត្តម អស់លោកក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០០៣

ជ.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ស ខេង

*<u>ចម្លងជូន</u>*

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-ទីស្តីការគណៈរដ្ឋមន្ត្រី*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីស ខេង*

*-ក្រសួងមហាផ្ទៃ*

*-ក្រសួងការពារជាតិ*

*-អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ*

*-អគ្គស្នងការដ្ឋាននគរបាលជាតិ*

*-បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស*

*-ដូចប្រការ១*

*-ឯកសារ-កាលប្បវត្តិ*